ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៧២...សសរ

# សេចក្តីសំរេច
## ស្តីពី
## ការតែងតាំង សមាជិក_សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

_បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការ បង្កើត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

_យោងតាមសំណើរបស់ ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## សំរេច

**ប្រការ ១._**

ត្រូវបានតែងតាំងជាសមាជិកភាព នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១.លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | ប្រធាន |
| ២.ឯកឧត្តម គង់ ម៉ុនធារិទ្ធ | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣.ឯកឧត្តម ខួត លុច | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤.លោកជំទាវ យូ អយ | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិកា |
| ៥.លោកជំទាវ ប្រាក់ ចន្ថា | រដ្ឋលេខាធិការ ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ៦.លោកជំទាវ ស៊ិន ស៊ី | អគ្គលេខាធិការរង រាជរដ្ឋាភិបាល | សមាជិកា |

៧.ឯកឧត្តម ម៉ក់ ទីរ៉ន់ រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៨. ឯកឧត្តម ម៉ិន ចន្ថា រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៩. អ្នកអង្គម្ចាស់ស៊ីសុវត្ថិ គុលាឧរាគ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១០. លោកជំទាវ អ៊ុក ម៉ុណ្ណា រដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិកា

១១ .ព្រះអង្គម្ចាស់ក្សត្រីយ៍ នរោត្តម តេនរេនទី រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិកា

១២. ឯកឧត្តម ថាច់ ដែន រដ្ឋលេខាធិការ ក្រសួងពត៌មាន សមាជិក

១៣. ឯកឧត្តម អ៊ូ ឱរាត រដ្ឋលេខាធិការ ក្រសួងផែនការ សមាជិក

១៤. ឯកឧត្តម ចាន់ មិន អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក

១៥. លោកជំទាវ អ៊ឹ ស៊ូម៉ារីន អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិកា

១៦. ឯកឧត្តម ឈី សៀមឡាក់ អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៧. លោកស្រី ចន្ទ ហារីនទដ្ឋី អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិកា

**ប្រការ២.-**

សមាជិក-សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នេះមានភារកិច្ច អនុវត្តការងារ ទៅតាមការតំរង់ទិស នៃព្រះរាជក្រឹត្យលេខ នស/រកត / ០២០១ / ០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៣.-**

សេចក្តីសំរេចលេខ ៧៣សសរ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីការតែងតាំងសមាជិក សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី-រដ្ឋលេខាធិការ -ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ១ និងប្រការ៤
- ឯកសារ-កាលប្បវត្តិ